# តើមានសញ្ញាអ្វីដែលចង្អុលប្រាប់ថាកុមារអាស្ថិតក្នុងហានិភ័យ?

## ១ ឥរិយាបទរបស់កុមារ

ក្នុងខណៈពេលដែលសញ្ញាទាំងនេះមិនបង្ហាញលក្ខណៈចាំបាច់ថាកុមារបាន ឬកំពុងត្រូវបានរំលោភបំពានក៏ដោយ តែពួកគេចាំបាច់ត្រូវយកចិត្តទុកដាក់លើស្ថានភាពដូចខាងក្រោម៖

- អារម្មណ៍យោលៗ ខ្លាយជាមនុស្សអៀនៗ/ចង់ឯកកោរពីគេ វាងព្រួយ/ស្រងោតស្រងាត់ ឆាប់ខឹង ឬឆាប់ឆេវឆាវ
- រត់ចេញពីផ្ទះ ឬបាត់ដំណឹងរយៈពេលយូរ
- មានការប្រែប្រួលការរៀនសូត្រ បាត់ពីសាលាដោយគ្មានមូលហេតុ
- បាន/មានលុយដោយឥតមូលហេតុ ការដូរ ទូរស័ព្ទ
- បំពានសារធាតុញៀន (ដូចជាជាតិសុរា ឬគ្រឿងញៀន)
- មានឥរិយាបទសិចស៊ីមិនសមនឹងអាយុរបស់គេ
- កុមារដែលគេឲ្យឈ្មោះ/ហៅថា "អ្នករំខាន" "Troublemaker"

## ២ ឥរិយាបទរបស់អ្នកដទៃចំពោះកុមារ

ត្រូវស្គាល់ឥរិយាបទរបស់មនុស្សធំនៅជុំវិញកុមារ។ ឥរិយាបទនេះអាចមានដូចជា៖ ការយកចិត្តទុកដាក់ហួសទំនង ការផ្តល់របស់របរ, សេចក្តីស្រឡាញ់ថ្នាក់ថ្នមលើសលុប ស្នើសុំឲ្យនៅម្នាក់ឯង ដើរទេសរនាមិនបាច់មានអ្នកគ្រប់គ្រង

## ៣ សញ្ញាលើរាងកាយ និងអាការៈសញ្ញា

សញ្ញាលើរាងកាយ និងអាការៈសញ្ញារួមមាន ការមានផ្ទៃពោះ របួសលើរូបកាយ ឬរបួសដោយសារការឆ្លង (រោគឆ្លងតាមការរួមភេទ និងជម្ងឺផ្សេងៗ)

## ៤ ការផ្តល់ព័ត៌មានពីកុមារ

នៅពេលខ្លះកុមារមានអាការៈមិនហ៊ាននិយាយជាមួយឪពុកម្តាយ ឬអ្នកថែទាំ (អាណាព្យាបាល) កុមារអាចប្រាប់មនុស្សធំដទៃដែលកុមារនោះទុកចិត្ត។

## ៥ សញ្ញាការព្រមាននៅសហគមន៍

នៅពេលដែលកុមាររស់នៅក្នុងសភាពលំបាក ពួកគេងាយរងគ្រោះដោយការរំលោភបំពាន។ នៅថ្នាក់សហគមន៍ត្រូវពិនិត្យមើលៈ ការសុំទានរបស់កុមារ, កុមារមិនទៅរៀន, រស់នៅ ឬធ្វើការនៅតាមដងផ្លូវ មិនមានការគ្រប់គ្រងគ្រប់គ្រាន់ពីឪពុកម្តាយ, រស់នៅក្នុងគ្រួសារងាយរងគ្រោះ, ញៀនជាមួយអ៊ីនធើណែត (Addicted to Internet) ឬល្បែង។ ក៏ត្រូវសម្លឹងមើលផងដែរចំពោះការកើនឡើងចំនួនមនុស្សធំ ឬកន្លែងកំសាន្តពេលរាត្រី ឬសេវាទេសចរណ៍ដែលភ្ជាប់ជាមួយឧស្សាហកម្មស៊ិច។